**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**លេខ** ......០២០២(ប្រ)..................**ក.ប/ស.ជ.ណ.ខ.ល**

# សេចក្តីជូនដំណឹង
# ស្តីពី
# ការជ្រើសរើសជនទេសន្តរប្រវេសន៍ការងារខ្មែរ
# ទៅធ្វើការនៅរដ្ឋអ៊ីស្រាអែល ក្នុងវិស័យកសិកម្ម

យោងលិខិត និងការឯកភាពរបស់អាជ្ញាធរប្រជាជន និងអន្តោប្រវេសន៍ (PIBA) នៃរដ្ឋអ៊ីស្រាអែលស្តីពីលក្ខខណ្ឌ និងនីតិវិធីជ្រើសរើសដើម្បីបំពេញតម្រូវការកម្លាំងពលកម្មកម្ពុជាសម្រាប់ទៅធ្វើការក្នុងវិស័យកសិកម្មនៅរដ្ឋអ៊ីស្រាអែល ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនដំណឹងដល់បងប្អូនដែលមានបំណងទៅធ្វើការនៅរដ្ឋអ៊ីស្រាអែលឱ្យបានជ្រាបថា ក្រសួងនឹងជ្រើសរើស បណ្តុះបណ្តាល និងបញ្ជូនជនទេសន្តរប្រវេសន៍ការងារខ្មែរទៅធ្វើការនៅរដ្ឋអ៊ីស្រាអែលក្នុងវិស័យកសិកម្ម ចំនួន ២ ០០០នាក់ ដោយមានលក្ខខណ្ឌ និងនីតិវិធីដូចខាងក្រោម៖

## ក. លក្ខខណ្ឌជ្រើសរើស

១.មានអាយុចន្លោះពី ២៣ ដល់ ៣៩ឆ្នាំ (គិតត្រឹមកាលបរិច្ឆេទដាក់ពាក្យ)
២.មានចំណេះដឹងភាសាអង់គ្លេសកម្រិតមូលដ្ឋាន។ បេក្ខជនដែលចេះភាសាហេព្រើរត្រូវបានផ្តល់អាទិភាព
៣.មានបទពិសោធន៍ការងារកសិកម្មនៅកសិដ្ឋាន ដែលមានសកម្មភាពប្រហាក់ប្រហែលនៅរដ្ឋអ៊ីស្រាអែល ដែលបញ្ជាក់ដោយអង្គភាពបញ្ជូននៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ (ប្រសិនបើមាន)
៤.បេក្ខជនដែលមានបទពិសោធន៍ការងារកសិកម្មស្របច្បាប់នៅសាធារណរដ្ឋកូរ៉េ ឬជប៉ុន ត្រូវបានផ្តល់អាទិភាព
៥.មានកាយសម្បទារឹងមាំ និងស្មារតីល្អ អាចបំពេញការងារក្រោមបរិយាកាសក្តៅនិងត្រជាក់ខ្លាំង និងនៅទីវាល នៅរដ្ឋអ៊ីស្រាអែល
៦.មិនមានសាច់ញាតិកម្រិតទី១ (ឪពុកម្តាយ កូន ប្តី/ប្រពន្ធ) កំពុងរស់នៅ ឬធ្វើការក្នុងរដ្ឋអ៊ីស្រាអែល (លើកលែង បងប្អូនបង្កើត)
៧.មិនធ្លាប់ទៅធ្វើការនៅរដ្ឋអ៊ីស្រាអែលពីមុន
៨.មិនមានជំងឺឆ្លង (របេង, រលាកថ្លើម B និង C, មេរោគអេដស៍ ឬកាមរោគ), មិនមានប្រវត្តិជំងឺបេះដូង, មិនមានជំងឺងងឹតពណ៌ភ្នែក, និងមិនមានពិការភាពផ្នែកអវយវៈ
៩.មានកិរិយាមារយាទជាពលរដ្ឋល្អ មិនធ្លាប់ប្រើប្រាស់គ្រឿងញៀន ឬញៀនគ្រឿងស្រវឹង
១០.មិនមានប្រវត្តិប្រព្រឹត្តបទល្មើស ឬជាប់ពន្ធនាគារ ឬទោសឧក្រិដ្ឋ។ សម្រាប់បេក្ខជនធ្លាប់ស្នាក់នៅបរទេសលើសពី ៦ខែ អាចតម្រូវឱ្យមានលិខិតបញ្ជាក់ពីប្រទេសនោះ (ប្រសិនបើមាន)
១១.បានវិលត្រឡប់មកកម្ពុជាវិញស្របច្បាប់យ៉ាងតិច ២ឆ្នាំ ចំពោះនិស្សិតដែលបានចូលរួមកម្មវិធីហាត់ការផ្នែកកសិកម្មនៅរដ្ឋអ៊ីស្រាអែល។



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

## ខ. កាលបរិច្ឆេទ និងទីកន្លែងចែកពាក្យ

- កាលបរិច្ឆេទ៖ ថ្ងៃទី១៨-១៩ ខែកក្កដា ឆ្នាំ២០២៦
- ម៉ោងធ្វើការ៖ វេនព្រឹក ម៉ោង៨:០០នាទី-១២:០០នាទី និងវេនរសៀល ម៉ោង១:០០នាទី-៥:០០នាទី
- ទីកន្លែង៖ វិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា (NPIC)
- តម្លៃពាក្យ៖ ១០ ០០០ (មួយម៉ឺន) រៀល

❖ បេក្ខជនត្រូវមកទទួលពាក្យដោយផ្ទាល់ និងត្រូវភ្ជាប់មកជាមួយនូវអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរច្បាប់ដើម។

## គ. កាលបរិច្ឆេទ និងទីកន្លែងទទួលពាក្យ

- កាលបរិច្ឆេទ៖ ចាប់ពីថ្ងៃទី២៧ ខែកក្កដា ដល់ថ្ងៃទី៧ ខែសីហា ឆ្នាំ២០២៦
- ម៉ោងធ្វើការ៖ វេនព្រឹក ម៉ោង៨:០០នាទី-១២:០០នាទី និងវេនរសៀល ម៉ោង១:០០នាទី-៥:០០នាទី
- ទីកន្លែង៖ វិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា (NPIC)

❖ **បេក្ខជនត្រូវមកដាក់ពាក្យដោយផ្ទាល់ និងត្រូវភ្ជាប់ឯកសារដូចខាងក្រោម៖**

១. អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរថតចម្លងពណ៌ធម្មជាតិ ចំនួន ៣ច្បាប់
២. សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅថតចម្លងសខ្មៅ ចំនួន ២ច្បាប់
៣. សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត ចំនួន ២ច្បាប់ និងថតចម្លងសខ្មៅ ចំនួន ២ច្បាប់
៤. រូបថតទំហំ ៥x៥ (ផ្ទៃក្រោយពណ៌ស) ចំនួន ៤សន្លឹក
៥. លិខិតឆ្លងដែនថតចម្លងពណ៌ធម្មជាតិ ចំនួន ៤ច្បាប់ (ប្រសិនបើមាន)
៦. លិខិតធានាអះអាងបេក្ខជន ចំនួន ១ច្បាប់
៧. លិខិតធានាអះអាងអាណាព្យាបាល ចំនួន ១ច្បាប់
៨. លិខិតបញ្ជាក់បុគ្គលិកលក្ខណៈនៃបេក្ខជន ចំនួន ១ច្បាប់
៩. លិខិតបញ្ជាក់ការងារផ្នែកកសិកម្មនៅតាមកសិដ្ឋាន ចំនួន ១ច្បាប់
១០. ឯកសារបញ្ជាក់ធ្លាប់ទៅធ្វើការផ្នែកកសិកម្មនៅសាធារណរដ្ឋកូរ៉េ ឬជប៉ុន (ប្រសិនបើមាន)
១១. វិញ្ញាបនបត្រភាសាអង់គ្លេស ឬហេព្រើរ (ប្រសិនបើមាន)។

## ឃ. ការប្រកាសបេក្ខជនមកសម្ភាស

បញ្ជីឈ្មោះបេក្ខជនដែលត្រូវបានជ្រើសរើសមកសម្ភាសនឹងត្រូវប្រកាសផ្សព្វផ្សាយតាមរយៈបណ្តាញផ្សព្វផ្សាយផ្លូវការរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលមាន QR Code ខាងក្រោម។

## ង. ព័ត៌មានសំខាន់ៗ

- បេក្ខជនជាបុរស នឹងត្រូវបានជ្រើសរើសភាគច្រើន
- និយោជកអ៊ីស្រាអែល គឺជាអ្នកជួលបេក្ខជនឱ្យធ្វើការ ហើយទទួលខុសត្រូវចំពោះប្រាក់ឈ្នួល និងលក្ខខណ្ឌការងារផ្សេងៗរបស់បេក្ខជន។ រដ្ឋអ៊ីស្រាអែល មិនមែនជាអ្នកជួលបេក្ខជនឱ្យធ្វើការឡើយ
- ប្រាក់ឈ្នួលអប្បបរមាប្រចាំខែនៅរដ្ឋអ៊ីស្រាអែល គឺប្រមាណ ២ ១០០ ដុល្លារអាមេរិក (អាចប្រែប្រួលតាមអត្រាប្តូរប្រាក់ជាក់ស្តែង) និងតម្រូវឱ្យមានការកាត់ប្រាក់ឈ្នួលជាកាតព្វកិច្ចតាមច្បាប់ ដូចជា ថ្លៃធានារ៉ាប់រងសុខភាព ទីកន្លែងស្នាក់នៅនិងថ្លៃទឹកភ្លើង ពន្ធលើប្រាក់ចំណូល និងធានារ៉ាប់រងផ្សេងៗ
- បេក្ខជនដែលបានដាក់ពាក្យទាំងអស់នឹងមិនប្រាកដថាអាចទៅធ្វើការនៅរដ្ឋអ៊ីស្រាអែលឡើយ។ រដ្ឋអ៊ីស្រាអែលនឹងជ្រើសរើសបេក្ខជនយ៉ាងច្រើនបំផុតចំនួន ៧៥% នៃបេក្ខជនបានសម្ភាសជាប់

- យោងតាមកិច្ចព្រមព្រៀងជាមួយរដ្ឋអ៊ីស្រាអែល បេក្ខជនត្រូវចំណាយសរុបទាំងអស់ប្រមាណ ៣ ៨០០ដុល្លារអាម៉េរិក (អាចប្រែប្រួលតាមអត្រាប្តូរប្រាក់ជាក់ស្តែង) លើសំណុំឯកសារចាំបាច់ ការបណ្តុះបណ្តាល សំបុត្រយន្តហោះពីកម្ពុជាទៅរដ្ឋអ៊ីស្រាអែល សេវារដ្ឋបាល និងសេវាថែទាំ ដែលត្រូវបង់ឱ្យទីភ្នាក់ងារជ្រើសរើសនៅរដ្ឋអ៊ីស្រាអែល
- រយៈពេលធ្វើការងារអតិបរមារបស់ជនទេសន្តរប្រវេសន៍ការងារខ្មែរនៅរដ្ឋអ៊ីស្រាអែល មានចំនួន ៦៣ខែ គិតចាប់ពីថ្ងៃដំបូងចូលទៅរដ្ឋអ៊ីស្រាអែល
- រដ្ឋអ៊ីស្រាអែល គឺជាប្រទេសដែលអាចស្ថិតក្នុងភាពមានអាសន្ន និងមានសកម្មភាពយោធាកើតឡើងនៅភាគខាងជើង និងភាគខាងត្បូង
- បេក្ខជននឹងត្រូវបានថតរូបដើម្បីផ្ទៀងផ្ទាត់អត្តសញ្ញាណ។

ក្រសួងសូមបញ្ជាក់ថា ការជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងជនទេសន្តរប្រវេសន៍ការងារខ្មែរទៅធ្វើការនៅរដ្ឋអ៊ីស្រាអែលក្នុងវិស័យកសិកម្ម គឺជាយន្តការបញ្ជូនរដ្ឋនិងរដ្ឋ រវាងរាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈជាប្រតិបត្តិករតែមួយគត់ និងរដ្ឋាភិបាលនៃរដ្ឋអ៊ីស្រាអែល។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងប្រព័ន្ធ Hotline លេខ ១២៩៧ ឬក្រុមតេឡេក្រាម "សម្រាប់ ពលករទេសន្តរប្រវេសន៍" ដែលមាន QR Code ខាងក្រោម ឬតាមរយៈទូរសព្ទលេខ +៨៥៥ ៧០ ៣១៣ ៥០៥/+៨៥៥ ៨៩ ៩៥៧ ៧៨៩ នៅរៀងរាល់ម៉ោងធ្វើការ។

ថ្ងៃ ព្រហស្បតិ៍ ១០រោច ខែ បឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ២០២៦

**រដ្ឋមន្ត្រី**

**ហេង សួរ**

បណ្តាញផ្សព្វផ្សាយផ្លូវការ
ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

សៀវភៅណែនាំស្តីពី
សិទ្ធិពលករបរទេសនៅរដ្ឋអ៊ីស្រាអែល
និងគំរូកិច្ចសន្យាការងារស្តង់ដា

**ចម្លងជូន៖**
-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
-ក្រសួងមហាផ្ទៃ
-ក្រសួង ស្ថាប័នពាក់ព័ន្ធ
-រដ្ឋបាលរាជធានី ខេត្ត
-មន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី ខេត្ត
-ឯកសារ កាលប្បវត្តិ